KB PRASAC Bank

ធនាគារ ខេប៊ីប្រាសាក់ ម.ក

លក្ខខណ្ឌនៃការប្រើប្រាស់គណនីក្រុម

Terms and Conditions of Using Group Account

ចោះពុម្ពលើកទី ១

មាតិកា

1. សេចក្តីផ្តើម (Introduction) 1
2. និយមន័យនៃពាក្យគន្លឹះ (Key Terms) 1
3. មធ្យោបាយក្នុងការបើកគណនីក្រុម (Opening Channel) 2
4. មធ្យោបាយក្នុងការអញ្ជើញសមាជិកមកចូលរួមក្នុងគណនីក្រុម (Invitation Channel) 3
5. មធ្យោបាយក្នុងការធ្វើប្រតិបត្តិការលើគណនីក្រុម (Transaction Channel) 3
6. រូបិយប័ណ្ណ (Currency) 3
7. ទឹកប្រាក់ដាក់ដំបូង និងសមតុល្យអប្បបរមា (Initial and Minimum Balance) 3
8. ទំហំទឹកប្រាក់ក្នុងគណនី និងទំហំប្រតិបត្តិការ (Account and Transaction Limit) 3
9. ចំនួនគណនីក្រុម (Number of Group Account) 3
10. រយៈពេលដាក់ប្រាក់បញ្ញើ (Deposit Term) 3
11. អត្រាការប្រាក់ (Interest Rate) 4
12. ពន្ធកាត់ទុក (Withholding Tax) 4
13. លក្ខខណ្ឌបើកគណនីក្រុម (Conditions of Opening Group Account) 4
14. ចំនួនសមាជិករួមគណនីក្រុម (Number of Members) 5
15. ការដាក់ប្រាក់បញ្ញើ (Deposit) 5
16. ការដកប្រាក់បញ្ញើ (Withdrawal) 5
17. ការបន្ថែមសមាជិក (Add Member) 6
18. ការដកសមាជិករួមគណនីក្រុម (Remove Member) 6
19. ការស្នើសុំចាកចេញពីគណនីក្រុម (Leave Group Account) 6
20. ការបិទគណនីក្រុម (Group Account Closing) 7
21. គណនីគ្មានប្រតិបត្តិការ (Dormant Account) 7
22. ការបង្ខាំង និងដោះបង្ខាំងគណនីក្រុម/សមតុល្យគណនីក្រុម (Block & Unblock Account/Balance) 7
23. សិទ្ធិ និងតួនាទីរបស់ម្ចាស់គណនីច្បង (Rights and Obligation of Primary) 8
24. សិទ្ធិ និងតួនាទីរបស់សមាជិករួមគណនីក្រុមដែលមានសិទ្ធិ «ពេញលេញ/Full Access» 8
25. សិទ្ធិ និងតួនាទីរបស់សមាជិករួមគណនីក្រុមដែលមានសិទ្ធិត្រឹម «ពិនិត្យព័ត៌មាន/View Only» 9
26. ការជូនដំណឹង (Notification) 9
27. ការដោះស្រាយវិវាទសម្រាប់អតិថិជន (Dispute Resolution) 10
28. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (Anti-Money Laundering and Combating Financing Terrorism) 10
29. ការកែប្រែ អត្រាការប្រាក់ កម្រៃសេវា លក្ខខណ្ឌ និងការជូនដំណឹង 11

(Amendment of Interest Rate, Fees, Conditions and Notification) 11

30. ច្បាប់ និងការដោះស្រាយវិវាទ (Law and Dispute Resolutions) 11

31. វិភាគភាព (Severability)..... 12
32. ភាសា (Language)..... 12

1. **សេចក្តីផ្តើម** (Introduction)

លក្ខខណ្ឌនៃការប្រើប្រាស់គណនីក្រុម តទៅហៅថា «លក្ខខណ្ឌប្រើប្រាស់» គឺជាកិច្ចព្រមព្រៀងរវាង លោក-លោកស្រី ជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក ហៅកាត់ថា **«ខេប៊ីប្រាសាក់»** ក្នុងការប្រើប្រាស់ផលិតផលនេះ។

សូម លោក-លោកស្រី អានលក្ខខណ្ឌនេះដោយប្រុងប្រយ័ត្ន មុននឹងចុចលើប៊ូតុង **«យល់ព្រម»** ដើម្បីបន្តលើការបើក និងប្រើប្រាស់ **គណនីក្រុម** តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

នៅពេល លោក-លោកស្រី បានចុចលើប៊ូតុង **«យល់ព្រម»** មានន័យថា លោក-លោកស្រី បានអាន បានយល់ និងព្រមអនុវត្តនូវគ្រប់លក្ខខណ្ឌដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ និងទទួលខុសត្រូវលើការបើក និងប្រើប្រាស់ **គណនីក្រុម** តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល និងមធ្យោបាយផ្សេងៗទៀតដែលបានផ្តល់ដោយធនាគារ។

2. **និយមន័យនៃពាក្យគន្លឹះ** (Key Terms)

- **លោក-លោកស្រី** ៖ សំដៅដល់ ម្ចាស់គណនីច្បង និងគ្រប់សមាជិករួមគណនីផ្សេងទៀត ដែលបានចូលរួមប្រើប្រាស់គណនីក្រុមតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។
- កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល KB PRASAC Mobile ៖ សំដៅលើ កម្មវិធីនៅលើទូរស័ព្ទចល័ត ដែលអនុញ្ញាតឱ្យ លោក-លោកស្រី អាចធ្វើប្រតិបត្តិការលើគណនីរបស់ខ្លួនបានដោយសុវត្ថិភាព នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា (24/7) រួមមានប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់វិក្កយបត្រ បើកគណនី និងប្រតិបត្តិការផ្សេងៗជាច្រើនទៀត ។
- គណនីក្រុម Group Account ៖ គឺជាប្រភេទគណនីប្រាក់បញ្ញើសន្សំ ដែលលោក-លោកស្រីអាចធ្វើការបើកគណនីបានដោយខ្លួនឯងតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/KB PRASAC Mobile»។ អ្នកបង្កើតគណនីក្រុម ត្រូវចាត់ទុកថាជា «ម្ចាស់គណនីច្បង (Primary)» និងអាចអញ្ជើញអតិថិជនផ្សេងទៀត មកចូលរួមនៅក្នុង «គណនីក្រុម» ត្រូវបានចាត់ទុកថាជា «សមាជិក/Member)»។
- ម្ចាស់គណនីច្បង Primary ៖ ជាអតិថិជនដែលជាអ្នកបង្កើតគណនីក្រុម និងមានសិទ្ធិក្នុងការអញ្ជើញសមាជិកផ្សេងទៀតមកចូលរួមនៅក្នុងគណនីក្រុម ដែលហៅថា **«សមាជិក/Member)»**។ ម្ចាស់គណនីច្បងអាចកំណត់សិទ្ធិសមាជិកនីមួយៗដើម្បីប្រើប្រាស់គណនីក្រុមនៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ជាមួយសិទ្ធិ «ពេញលេញ/Full Access» ឬ «ពិនិត្យព័ត៌មាន /View Only» ទៅតាមតម្រូវការជាក់ស្តែង។ ម្ចាស់គណនីច្បង អាចជា «អតិថិជនពេញលេញ/Full KYC» ឬ «អតិថិជនមិនពេញលេញ/Partial KYC»។

- ❖ សមាជិក Member ៖ ជាអតិថិជន ដែលត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងគណនីក្រុមដោយ «ម្ចាស់គណនីច្បង» ទៅតាមតម្រូវការប្រើប្រាស់គណនីជាក់ស្តែង។ សមាជិក មានសិទ្ធិយល់ព្រម (Accept) ឬ បដិសេធ (Reject) លើសំណើស្នើសុំឱ្យចូលរួមនៅក្នុងគណនីក្រុមបាន។ សមាជិកអាចជា «អតិថិជនពេញលេញ/Full KYC» ឬ «អតិថិជនមិនពេញលេញ/Partial KYC»។
- ❖ អតិថិជនពេញលេញ Full KYC ៖ ជាអតិថិជន ដែលបានផ្តល់ព័ត៌មានពេញលេញមកខេប៊ីប្រាសាក់ដោយយោងតាមវិធាននៃការយកចិត្តទុកដាក់ស្គាល់អតិថិជន (Know Your Customer)៖
  - ការទទួលបានព័ត៌មានពេញលេញពីអតិថិជន៖ ព័ត៌មានផ្ទាល់ខ្លួន លេខទំនាក់ទំនង មុខរបរ ប្រភពចំណូល។ល។
  - គោលបំណង នៃការបើកគណនី និង
  - ទទួលបានការផ្ទៀងផ្ទាត់ព័ត៌មានផ្សេងៗទៀតដោយផ្ទាល់ពីបុគ្គលទៅតាមលក្ខខណ្ឌតម្រូវរបស់ខេប៊ីប្រាសាក់។
- ❖ អតិថិជនមិនពេញលេញ Partial KYC ៖ អតិថិជន ដែលបានចុះឈ្មោះបើក **គណនីឌីជីថល** តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល និងបានបំពេញព័ត៌មានសំខាន់ៗដូចជា៖ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន លេខអត្តសញ្ញាណប័ណ្ណ លេខទូរស័ព្ទ ថតរូប សែលហ្វីថតរូបអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាព និងព័ត៌មានផ្សេងៗទៀតទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។ អតិថិជនប្រភេទនេះអាចធ្វើប្រតិបត្តិការប្រចាំថ្ងៃទៅតាមទំហំកំណត់ជាក់លាក់មួយ ដែលត្រូវបានកំណត់ដោយខេប៊ីប្រាសាក់ (ទំហំតូចជាងអតិថិជនប្រភេទជា Full KYC) ។
- ❖ សិទ្ធិ «ពេញលេញ» Full Access ៖ ជាសិទ្ធិធ្វើប្រតិបត្តិការលើ គណនីក្រុម ជាមួយប្រតិបត្តិការហិរញ្ញវត្ថុ (ការផ្ទេរប្រាក់ ការទូទាត់...) និងប្រតិបត្តិការមិនមែនហិរញ្ញវត្ថុតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile) ។
- ❖ សិទ្ធិ «ពិនិត្យព័ត៌មាន» View Only ៖ ជាសិទ្ធិត្រឹមពិនិត្យព័ត៌មានគណនី ពិនិត្យរបាយការណ៍គណនី និងព័ត៌មានផ្សេងៗទៀតរបស់គណនីក្រុម ដោយមិនមានសិទ្ធិធ្វើប្រតិបត្តិការហិរញ្ញវត្ថុណាមួយលើគណនីក្រុមតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile) បានឡើយ។

3. **មធ្យោបាយក្នុងការបើកគណនីក្រុម** (Opening Channel)

- លោក-លោកស្រី អាចធ្វើការបើកគណនីក្រុមបានតាមរយៈ **«កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/KB PRASAC Mobile»** នៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

4. **មធ្យោបាយក្នុងការអញ្ជើញសមាជិកមកចូលរួមក្នុងគណនីក្រុម** (Invitation Channel)
   - លោក-លោកស្រី អាចអញ្ជើញសមាជិកមកចូលរួមក្នុងគណនីក្រុមបានតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/ KB PRASAC Mobile» នៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

5. **មធ្យោបាយក្នុងការធ្វើប្រតិបត្តិការលើគណនីក្រុម** (Transaction Channel)
   - លោក-លោកស្រី អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុនៅលើគណនីក្រុមបាន តាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/KB PRASAC Mobile» ដោយប្រើប្រាស់យោងទៅតាមមុខងារនីមួយៗនៃកម្មវិធី។

6. **រូបិយប័ណ្ណ** (Currency)
   6.1. លោក-លោកស្រី អាចជ្រើសរើសបើកគណនីក្រុមជាមួយរូបិយប័ណ្ណចំនួន 02 (ពីរ) ប្រភេទ រួមមាន៖
      - ❖ ប្រាក់រៀល (KHR) និង
      - ❖ ប្រាក់ដុល្លារអាមេរិក (USD) ។
   6.2. ករណីធ្វើប្រតិបត្តិការឆ្លងរូបិយប័ណ្ណ ត្រូវយោងទៅតាមអត្រាប្តូរប្រាក់ជាក់ស្តែងរបស់ខេប៊ីប្រាសាក់នៅថ្ងៃធ្វើប្រតិបត្តិការនោះ។

7. **ទឹកប្រាក់ដាក់ដំបូង និងសមតុល្យអប្បបរមា** (Initial and Minimum Balance)
   - មិនតម្រូវទឹកប្រាក់ដាក់ដំបូង និងសមតុល្យអប្បបរមា សម្រាប់ការបើក និងរក្សាទុកក្នុងគណនីក្រុមឡើយ។

8. **ទំហំទឹកប្រាក់ក្នុងគណនី និងទំហំប្រតិបត្តិការ** (Account and Transaction Limit)
   - ទំហំទឹកប្រាក់ក្នុងគណនី និងទំហំទឹកប្រាក់សម្រាប់ធ្វើប្រតិបត្តិការលើគណនីក្រុមតាមរយៈ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល គឺត្រូវបានកំណត់ដោយផ្អែកទៅតាមប្រភេទអតិថិជនដែលជា «ម្ចាស់គណនីច្បង» ជាប្រភេទ «អតិថិជនពេញលេញ/Full KYC» ឬ «អតិថិជនមិនពេញលេញ/Partial KYC» ។

9. **ចំនួនគណនីក្រុម** (Number of Group Account)
   - «ម្ចាស់គណនីច្បង/Primary»៖ អតិថិជនម្នាក់ អាចបើកគណនីក្រុម និងធ្វើជា «ម្ចាស់គណនីច្បង/Primary» បានរហូតដល់ 20 គណនីក្រុម។
   - «សមាជិក/Member»៖ អតិថិជនម្នាក់ អាចធ្វើជា «សមាជិក/Member» ក្នុងគណនីក្រុមដោយមិនកំណត់ចំនួនគណនីឡើយ។

10. **រយៈពេលដាក់ប្រាក់បញ្ញើ** (Deposit Term)
    - មិនមានរយៈពេលកំណត់លើការដាក់ប្រាក់បញ្ញើនៅក្នុង គណនីក្រុម ឡើយ។
    - លោក-លោកស្រី អាចប្រើប្រាស់គណនីក្រុមសម្រាប់ការទូទាត់ផ្សេងៗរហូតដល់គណនីត្រូវបានបិទ។

11. **អត្រាការប្រាក់** (Interest Rate)

11.1. អត្រាការប្រាក់ត្រូវបានផ្តល់ជូនទៅតាមសមតុល្យដែលមានជាក់ស្តែងនៅក្នុងគណនី។

11.2. ការប្រាក់នឹងត្រូវបានបង្គរជាប្រចាំថ្ងៃ និងទូទាត់ចូលទៅក្នុងគណនីក្រុម នៅរៀងរាល់ដើមខែ ឬ នៅពេលបិទគណនី។

11.3. លោក-លោកស្រី អាចស្វែងរកព័ត៌មាននៃអត្រាការប្រាក់បាននៅតាមសាខាខេប៊ីប្រាសាក់ និង/ឬ វេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់ www.kbprasacbank.com.kh ។

12. **ពន្ធកាត់ទុក** (Withholding Tax)

12.1. ការប្រាក់ ដែលទទួលបានពីទំហំទឹកប្រាក់នៅក្នុងគណនីនឹងត្រូវជាប់កាតព្វកិច្ចពន្ធកាត់ទុក ឬ ពន្ធផ្សេងៗតាមច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តិជាធរមាន។

12.2. **ពន្ធកាត់ទុក** ជាបន្ទុករបស់ លោក-លោកស្រី និងយល់ព្រមឱ្យ ខេប៊ីប្រាសាក់ ទូទាត់ **ពន្ធកាត់ទុក** ចេញពីគណនីក្រុមរបស់ លោក-លោកស្រី ដោយស្វ័យប្រវត្តិនៅរៀងរាល់ពេលដែល ខេប៊ីប្រាសាក់ បានបញ្ចូលការប្រាក់ជូន លោក-លោកស្រី។

12.3. អត្រាពន្ធកាត់៖

- **4% សម្រាប់និវាសនជន**
- **14% សម្រាប់អនិវាសនជន**

13. **លក្ខខណ្ឌបើកគណនីក្រុម** (Conditions of Opening Group Account)

13.1. លោក-លោកស្រី អាចធ្វើការបើក «គណនីក្រុម» បានដោយខ្លួនឯងនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល នៅលើទូរស័ព្ទចល័តរបស់ខ្លួន។

13.2. លោក-លោកស្រី ដែលជាអ្នកធ្វើការបើកគណនីក្រុម ត្រូវចាត់ទុកជា «ម្ចាស់គណនីច្បង/Primary» ចំណែក ឯ លោក-លោកស្រី ដែលត្រូវបានអញ្ជើញឱ្យមករួមគណនីក្រុមត្រូវចាត់ទុកជា «សមាជិក/Member»។

13.3. ម្ចាស់គណនីច្បង មានសិទ្ធិប្រើប្រាស់គណនីក្រុមតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ជាមួយសិទ្ធិ «ពេញលេញ/Full Access» ដោយស្វ័យប្រវត្តិ។

13.4. ម្ចាស់គណនីច្បង អាចកំណត់សិទ្ធិប្រើប្រាស់គណនីក្រុម សម្រាប់ «សមាជិក/Member» ទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ករណីសមាជិក ជាប្រភេទ «អតិថិជនពេញលេញ/Full KYC» ៖ អាចកំណត់សិទ្ធិប្រើប្រាស់គណនីក្រុមតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ជាមួយសិទ្ធិ «ពេញលេញ/Full Access» ឬ «ពិនិត្យព័ត៌មាន/View only» ។
- ករណីសមាជិក ជាប្រភេទ «អតិថិជនមិនពេញលេញ/Partial KYC» ៖ អាចកំណត់សិទ្ធិប្រើប្រាស់គណនីក្រុមតាមរយៈ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ត្រឹមសិទ្ធិ «ពិនិត្យព័ត៌មាន/View only» តែប៉ុណ្ណោះ។

13.5. ករណី «សមាជិក/Member» មិនទាន់មានគណនីណាមួយជាមួយខេប៊ីប្រាសាក់ សមាជិកនោះអាចធ្វើការបង្កើតគណនីឌីថល (Digital Account) បន្ទាប់មកអាចទទួលការអញ្ជើញរបស់ «ម្ចាស់គណនីច្បង/Primary» ក្នុងការចូលរួមនៅក្នុងគណនីក្រុមបាន។

13.6. «សមាជិក/Member» មានសិទ្ធិក្នុងការទទួលយកសំណើ ឬ បដិសេធសំណើនៃការស្នើសុំចូលរួមគណនីក្រុមក្នុងរយៈពេល 48 ម៉ោង។ ករណីលើសរយៈពេល 48 ម៉ោង មិនមានការឆ្លើយតប សំណើនឹងត្រូវផុតសុពលភាពដោយស្វ័យប្រវត្តិ។

13.7. ម្ចាស់គណនីច្បង អាចកំណត់ឈ្មោះគណនី (Rename Group Account) នៅពេលបង្កើតគណនីក្រុម។

13.8. ម្ចាស់គណនីច្បង អាចធ្វើការផ្លាស់ប្តូរឈ្មោះគណនីក្រុម (Rename Account) ទៅឈ្មោះផ្សេងបន្ទាប់ពីគណនីក្រុមបង្កើតបានដោយជោគជ័យ។

13.9. ឈ្មោះគណនីដែលបានផ្លាស់ប្តូរ អាចមើលឃើញតែនៅក្នុងកម្មវិធីខេប៊ីប្រាសាក់ម៉ូបាលតែប៉ុណ្ណោះ។ រាល់របាយការណ៍ពាក់ព័ន្ធ ដូចជា របាយការណ៍គណនី និង ឯកសារផ្លូវការផ្សេងៗ គឺត្រូវយក «ឈ្មោះម្ចាស់គណនីច្បង» ជាឈ្មោះគណនី (Account Name) ។

14. ចំនួនសមាជិករួមគណនីក្រុម (Number of Members)

14.1. ក្នុងគណនីក្រុមមួយ អនុញ្ញាតឱ្យមានសមាជិកក្នុងគណនីក្រុមបានរហូតដល់ 20 នាក់ បូករួមទាំងម្ចាស់គណនីច្បង និងសមាជិករួមគណនីក្រុម។

14.2. ក្នុងគណនីក្រុមមួយ អាចកំណត់សិទ្ធិ «សមាជិក» ឱ្យមានសិទ្ធិ «ពេញលេញ/Full Access» សម្រាប់ប្រើប្រាស់កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល បានរហូតដល់ 05 នាក់ ដែលក្នុងនោះក៏មានរួមបញ្ចូល ម្ចាស់គណនីច្បងម្នាក់ផងដែរ។

15. ការដាក់ប្រាក់បញ្ញើ (Deposit)

លោក-លោកស្រី អាចធ្វើការដាក់ប្រាក់ចូលទៅក្នុងគណនីក្រុមទៅតាមមធ្យោបាយណាមួយខាងក្រោម៖

- នៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់ ឬ
- ផ្ទេរចូលតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ
- ផ្ទេរចូលតាមរយៈសេវាខេប៊ីប្រាសាក់ឧបភោគ ឬ
- ម៉ាស៊ីនឆូតកាត ឬ
- ម៉ាស៊ីនដាក់ប្រាក់ ឬ
- ទទួលការផ្ទេរប្រាក់ចូលពីធនាគារផ្សេង (ក្នុងស្រុក ឬ ក្រៅស្រុក)។ល។

16. ការដកប្រាក់បញ្ញើ (Withdrawal)

16.1. ម្ចាស់គណនីច្បង ឬ សមាជិកដែលមានសិទ្ធិ «ពេញលេញ /Full Access» ណាម្នាក់ អាចធ្វើគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុលើគណនីក្រុមតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល» ដោយយោងទៅតាមមុខងារនៃកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

16.2. ករណី លោក-លោកស្រី ចង់ដកជាសាច់ប្រាក់ លោក-លោកស្រីអាច៖

- ប្រើមុខងារ «ផ្ទេរប្រាក់តាមលេខកូដសម្ងាត់ (Cash-Code)» នៅលើកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ដើម្បីទទួលបានលេខកូដ 06 ខ្ទង់ ក្នុងការដកប្រាក់តាមទូអេធីអឹមខេប៊ីប្រាសាក់ ឬ
- ធ្វើប្រតិបត្តិការស្កេន QR ដកប្រាក់ តាមម៉ាស៊ីនអេធីអឹមរបស់ខេប៊ីប្រាសាក់ ដើម្បីដកជាសាច់ប្រាក់។

16.3. ក្នុងករណីលោក-លោកស្រី ចង់ដកជាសាច់ប្រាក់ចេញពីគណនីក្រុមតាមរយៈបញ្ជារបេឡា លោក-លោកស្រីត្រូវធ្វើការផ្ទេរប្រាក់ទៅគណនីផ្សេង ដែលមានគំរូហត្ថលេខា បន្ទាប់មកអាចធ្វើប្រតិបត្តិការដកប្រាក់នៅតាមបញ្ជារបេឡាបាន។

17. ការបន្ថែមសមាជិក (Add Member)

17.1. ម្ចាស់គណនីច្បង ឬ សមាជិក ដែលមានសិទ្ធិ «ពេញលេញ/Full Access» អាចធ្វើការអញ្ជើញសមាជិកថ្មីមកចូលរួមនៅក្នុងគណនីក្រុម តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាលបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

17.2. ការស្នើសុំបន្ថែមសមាជិកតម្រូវឱ្យមានការយល់ព្រមពីម្ចាស់គណនីច្បង គ្រប់សមាជិកដែលមានសិទ្ធិ «ពេញលេញ/Full Access» ព្រមទាំងសមាជិកថ្មីដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងគណនីផងដែរ។

17.3. ករណីម្ចាស់គណនីច្បង និង/ឬ សមាជិកមានសិទ្ធិ «ពេញលេញ/Full Access» ណាម្នាក់ និង/ឬ សមាជិកថ្មីដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងគណនី បដិសេធ ឬ មិនឆ្លើយតបសំណើក្នុងរយៈ 48 ម៉ោង នោះសំណើនឹងត្រូវបានមោឃភាពដោយស្វ័យប្រវត្តិ។

18. ការដកសមាជិករួមគណនីក្រុម (Remove Member)

18.1. ម្ចាស់គណនីច្បង ឬ សមាជិកដែលមានសិទ្ធិ «ពេញលេញ/Full Access» អាចស្នើសុំដកសិទ្ធិសមាជិកណាម្នាក់ចេញពីគណនីក្រុម តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។

18.2. ការស្នើសុំដកសិទ្ធិសមាជិកណាម្នាក់តម្រូវឱ្យមានការយល់ព្រមពីម្ចាស់គណនីច្បង និង សមាជិកផ្សេងទៀតដែលមានសិទ្ធិ «ពេញលេញ/Full Access» រួមទាំងសមាជិកដែលត្រូវបានស្នើសុំដកសិទ្ធិចេញនោះផងដែរ។

18.3. ករណី ម្ចាស់គណនីច្បង និង/ឬ សមាជិករួមគណនីណាម្នាក់ ឬ សមាជិកដែលត្រូវបានស្នើសុំដកសិទ្ធិចេញ ធ្វើការបដិសេធលើសំណើ ឬ មិនឆ្លើយតបសំណើលើសពី 48 ម៉ោង នោះសំណើនឹងត្រូវបានមោឃភាពដោយស្វ័យប្រវត្តិ។

18.4. មិនអនុញ្ញាតឱ្យធ្វើការដកសិទ្ធិ «ម្ចាស់គណនីច្បង» ចេញពីគណនីក្រុមឡើយ ទោះបីស្នើសុំដោយម្ចាស់គណនីច្បងដោយផ្ទាល់ ឬ សមាជិកដែលមានសិទ្ធិ «ពេញលេញ/Full Access» ណាម្នាក់ក៏ដោយ។

19. ការស្នើសុំចាកចេញពីគណនីក្រុម (Leave Group Account)

19.1. គ្រប់សមាជិកទាំងអស់ (Full Access ឬ View Only) អាចស្នើសុំ «ចាកចេញ/Leave» ពីគណនីក្រុមបានដោយខ្លួនឯងតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល តែតម្រូវឱ្យមានការយល់ព្រមពីម្ចាស់គណនីច្បង និងគ្រប់សមាជិករួមគណនីក្រុមផ្សេងទៀតដែលមានសិទ្ធិ «ពេញលេញ/Full Access»។

19.2. ក្នុងករណី ម្ចាស់គណនីច្បង ឬ សមាជិករួមគណនីក្រុមណាម្នាក់ដែលមានសិទ្ធិ «ពេញលេញ/Full Access» ធ្វើការបដិសេធលើសំណើ ឬ មិនឆ្លើយតបសំណើលើសពី 48 ម៉ោង នោះសំណើនឹងត្រូវបានមោឃភាពដោយស្វ័យប្រវត្តិ។

19.3. «ម្ចាស់គណនីច្បង» មិនអាចស្នើសុំចាកចេញពីគណនីក្រុម ដែលខ្លួនបានបង្កើតឡើងឡើយ។

20. ការបិទគណនីក្រុម (Group Account Closing)

20.1. មានតែ ម្ចាស់គណនីច្បង តែម្នាក់គត់ ដែលមានសិទ្ធិក្នុងការស្នើសុំបិទគណនីក្រុម។

20.2. ការស្នើសុំបិទគណនីក្រុម អាចធ្វើទៅបានតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល បានគ្រប់ពេលវេលា និងទីកន្លែង។

20.3. ការស្នើសុំបិទគណនីក្រុម តម្រូវឱ្យមានការយល់ព្រមពីគ្រប់សមាជិកទាំងអស់ដែលមានសិទ្ធិប្រើប្រាស់គណនី «ពេញលេញ/Full Access»។

20.4. សមតុល្យនៅក្នុងគណនីទាំងអស់បូករួមទាំងការប្រាក់នឹងត្រូវបានផ្ទេរទៅគណនីប្រភពណាមួយក្រោមម្ចាស់គណនីច្បង បន្ទាប់ពីសមាជិកទាំងអស់ដែលមានសិទ្ធិ «ពេញលេញ/Full Access» បានយល់ព្រមលើសំណើស្នើសុំបិទគណនី។

20.5. ករណីសមាជិករួមគណនីក្រុម ដែលមានសិទ្ធិ «ពេញលេញ/Full Access» ណាម្នាក់ ធ្វើការបដិសេធលើសំណើស្នើសុំបិទគណនីក្រុម ឬ មិនមានការឆ្លើយតបក្នុងរយៈពេល 48 ម៉ោង នោះគណនីក្រុមនឹងមិនអាចបិទបានដោយជោគជ័យឡើយ។

21. គណនីគ្មានប្រតិបត្តិការ (Dormant Account)

21.1. គណនីក្រុម ដែលមិនមានប្រតិបត្តិការក្នុងរយៈពេលចាប់ពី 365 ថ្ងៃ ឡើងទៅ គណនីនោះនឹងក្លាយទៅជាគណនីគ្មានប្រតិបត្តិការ។

21.2. លោក-លោកស្រី យល់ព្រមឱ្យខេប៊ីប្រាសាក់ធ្វើការទូទាត់កម្រៃសេវា គណនីគ្មានប្រតិបត្តិការជាប្រចាំខែ ដោយកម្រៃសេវានឹងត្រូវបានទូទាត់ចេញពីគណនីក្រុមដោយស្វ័យប្រវត្តិ។

21.3. គណនីក្រុមដែលមិនមានប្រតិបត្តិការរយៈពេល 10 ឆ្នាំជាប់គ្នា ខេប៊ីប្រាសាក់នឹងធ្វើការផ្ទេរសមតុល្យគណនីក្រុមទៅធនាគារជាតិ នៃ កម្ពុជា ដើម្បីគ្រប់គ្រងបន្តដោយអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

21.4. ម្ចាស់គណនីច្បង អាចធ្វើការបើកឱ្យដំណើរការគណនីក្រុមដែលគ្មានប្រតិបត្តិការតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ សាខាខេប៊ីប្រាសាក់ (ទៅតាមការកំណត់ដោយខេប៊ីប្រាសាក់) ដោយមិនតម្រូវឱ្យមានការយល់ព្រមពីសមាជិកដែលមានសិទ្ធិ «ពេញលេញ/Full Access» ផ្សេងទៀតឡើយ។

22. ការបង្ខាំង និងដោះបង្ខាំងគណនីក្រុម/សមតុល្យគណនីក្រុម (Block & Unblock Account/Balance)

22.1. ម្ចាស់គណនីច្បង និង សមាជិក (Member) ដែលមានសិទ្ធិ «ពេញលេញ/Full Access» ទាំងអស់ ត្រូវធ្វើការស្នើសុំបង្ខាំង ឬ ដោះបង្ខាំងគណនីក្រុម ឬ សមតុល្យគណនីក្រុម ជាលាយលក្ខណ៍អក្សរបាននៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់ ដោយត្រូវអនុវត្តទៅតាមលក្ខខណ្ឌ និងនីតិវិធីរបស់ខេប៊ីប្រាសាក់។

23. សិទ្ធិ និងតួនាទីរបស់ម្ចាស់គណនីច្បង (Rights and Obligation of Primary)

ម្ចាស់គណនីច្បង មានសិទ្ធិប្រើប្រាស់គណនីក្រុមតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល» ដូចខាងក្រោម៖

23.1. ម្ចាស់គណនីច្បង គឺជាអ្នកបង្កើតគណនីក្រុម។

23.2. មានសិទ្ធិធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុលើគណនីក្រុមតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល

23.3. មានសិទ្ធិបន្ថែមសមាជិក តែត្រូវមានការយល់ព្រមពីគ្រប់សមាជិក មានសិទ្ធិ «ពេញលេញ/Full Access» និងសមាជិកថ្មី។

23.4. មានសិទ្ធិដកសមាជិក តែត្រូវមានការយល់ព្រមពីគ្រប់សមាជិក មានសិទ្ធិ «ពេញលេញ/Full Access» និងសមាជិក ដែលត្រូវបានដកសិទ្ធិចេញពីគណនីក្រុម។

23.5. មានសិទ្ធិស្នើសុំ បង្ខាំង ឬ ដោះបង្ខាំងគណនីក្រុម ឬ សមតុល្យគណនីក្រុម ជាលាយលក្ខណ៍អក្សរបាន តែត្រូវមានការយល់ព្រមពីសមាជិករួមគណនីក្រុមផ្សេងទៀតដែលមានសិទ្ធិ «ពេញលេញ/Full Access»។

23.6. អាចធ្វើការផ្លាស់ប្តូរឈ្មោះគណនីក្រុម (Rename Account)។

23.7. មានសិទ្ធិស្នើសុំប្តូរកម្រិតសិទ្ធិប្រើប្រាស់គណនីក្រុម សម្រាប់គ្រប់សមាជិក ពី «ពេញលេញ/Full Access» ទៅ/មក «ពិនិត្យព័ត៌មាន/View Only» តែត្រូវមានការយល់ព្រមពីគ្រប់សមាជិកមានសិទ្ធិ «ពេញលេញ/Full Access» និងសមាជិកដែលត្រូវស្នើសុំប្តូរសិទ្ធិ។

23.8. អាចស្នើសុំបិទគណនីក្រុម តែត្រូវមានការយល់ព្រមពីសមាជិក ដែលមានសិទ្ធិ «ពេញលេញ/Full Access»។

23.9. មិនអាចចាកចេញពីគណនីក្រុម បានឡើយ។

23.10. សិទ្ធិផ្សេងៗទៀតទៅតាមលក្ខខណ្ឌតម្រូវនៃប្រព័ន្ធ។ល។

24. សិទ្ធិ និងតួនាទីរបស់សមាជិករួមគណនីក្រុមដែលមានសិទ្ធិ «ពេញលេញ/Full Access»
(Rights and Obligations of Member with "Full Access")

សមាជិករួមគណនីក្រុមដែលមានសិទ្ធិ «ពេញលេញ/Full Access» លើការប្រើប្រាស់គណនីក្រុមតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល» ដូចខាងក្រោម៖

24.1. មានសិទ្ធិធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុលើគណនីក្រុម ដូចម្ចាស់គណនីច្បង។

24.2. មានសិទ្ធិស្នើសុំបន្ថែមសមាជិក តែត្រូវមានការយល់ព្រមពីគ្រប់សមាជិកផ្សេងទៀត ដែលមានសិទ្ធិ «ពេញលេញ/Full Access» និងម្ចាស់គណនីច្បង និងសមាជិកថ្មីដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងគណនី។

24.3. មានសិទ្ធិស្នើសុំដកសមាជិករួមគណនីក្រុម តែមានការយល់ព្រមពីសមាជិករួមគណនីក្រុមផ្សេងទៀត ដែលមានសិទ្ធិ «ពេញលេញ/Full Access» និងម្ចាស់គណនីច្បង និងសមាជិកដែលត្រូវបានដកសិទ្ធិចេញពីគណនីក្រុម។

24.4. មានសិទ្ធិស្នើសុំដោះបង្ខាំងគណនីក្រុម ឬ សមតុល្យគណនីក្រុម ជាលាយលក្ខណ៍អក្សរបាននៅតាមសាខាណាមួយរបស់ខេប៊ីប្រាសាក់ តែចូលរួមពីគ្រប់សមាជិកផ្សេងទៀត ដែលមានសិទ្ធិ «ពេញលេញ/Full Access» និងម្ចាស់គណនីច្បង។

24.5. ស្នើសុំប្តូរកម្រិតសិទ្ធិប្រើប្រាស់គណនីក្រុម របស់សមាជិក ពី «ពេញលេញ/Full Access» ទៅ/មក «ពិនិត្យព័ត៌មាន/View Only» តែមានការយល់ព្រមពីគ្រប់សមាជិកផ្សេងទៀតមានសិទ្ធិ «ពេញលេញ/Full Access» ម្ចាស់គណនីច្បង និងសមាជិកដែលត្រូវស្នើសុំប្តូរសិទ្ធិ។

24.6. មានសិទ្ធិយល់ព្រម ឬ បដិសេធសំណើស្នើសុំដកសិទ្ធិរបស់ខ្លួន ឬ សមាជិកចេញពីគណនីក្រុម ដែលស្នើសុំដោយម្ចាស់គណនីច្បង ឬ សមាជិកផ្សេងទៀតដែលមានសិទ្ធិ «ពេញលេញ/Full Access»។

24.7. មានសិទ្ធិយល់ព្រម ឬ បដិសេធសំណើស្នើសុំប្តូរកម្រិតសិទ្ធិប្រើប្រាស់គណនីក្រុមរបស់ខ្លួន ឬ សមាជិក ដែលស្នើសុំដោយម្ចាស់គណនីច្បង ឬ សមាជិកផ្សេងទៀតដែលមានសិទ្ធិ «ពេញលេញ/Full Access»។

24.8. អាចចាកចេញពីគណនីក្រុម តែមានការយល់ព្រមពីគ្រប់សមាជិកផ្សេងទៀត ដែលមានសិទ្ធិ «ពេញលេញ/Full Access» និងម្ចាស់គណនីច្បង។

24.9. មិនមានសិទ្ធិស្នើសុំបិទគណនីក្រុមឡើយ។

25. សិទ្ធិ និងតួនាទីរបស់សមាជិករួមគណនីក្រុមដែលមានសិទ្ធិត្រឹម «ពិនិត្យព័ត៌មាន/View Only»

(Rights and Obligations of Member with "View Only")

សមាជិករួមគណនីក្រុមដែលមានសិទ្ធិត្រឹម «ពិនិត្យព័ត៌មាន/View Only» លើការប្រើប្រាស់គណនីក្រុមតាមរយៈ «កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល» ដូចខាងក្រោម៖

25.1. មានសិទ្ធិត្រឹមពិនិត្យសមតុល្យគណនី របាយការណ៍គណនី និងព័ត៌មានគណនីផ្សេងៗតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

25.2. អាចចាកចេញពីគណនីក្រុម តែត្រូវមានការយល់ព្រមពី ម្ចាស់គណនីច្បង និងសមាជិកផ្សេងទៀតដែលមានសិទ្ធិ «ពេញលេញ/Full Access»។

25.3. មិនអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានឡើយ ដូចជា ផ្ទេរប្រាក់ ទូទាត់ទំនិញ/សេវាកម្ម ទូទាត់វិក្កយបត្រ ឬ ប្រតិបត្តិការផ្សេងៗទៀត។

25.4. មានសិទ្ធិយល់ព្រម ឬ បដិសេធសំណើស្នើសុំដកសិទ្ធិរបស់ខ្លួន ចេញពីគណនីក្រុម ដែលស្នើសុំដោយម្ចាស់គណនីច្បង ឬ សមាជិកផ្សេងទៀតដែលមានសិទ្ធិ «ពេញលេញ/Full Access»។

25.5. មានសិទ្ធិយល់ព្រម ឬ បដិសេធសំណើស្នើសុំប្តូរកម្រិតសិទ្ធិប្រើប្រាស់គណនីក្រុមរបស់ខ្លួន ដែលស្នើសុំដោយម្ចាស់គណនីច្បង ឬ សមាជិកផ្សេងទៀតដែលមានសិទ្ធិ «ពេញលេញ/Full Access»។

25.6. មិនអាចស្នើសុំបិទគណនី ឬ បង្ខាំងគណនី ឬ ដោះបង្ខាំងគណនីឡើយ។ល។

26. ការជូនដំណឹង (Notification)

- ការជូនដំណឹង (Notification) ទៅកាន់ លោក-លោកស្រី តាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាលដើម្បីជ្រាបជាព័ត៌មានបន្ទាប់ពីសំណើ ឬ ប្រតិបត្តិការនោះទទួលបានជោគជ័យ នឹងត្រូវបានធ្វើទៅតាមប្រភេទប្រតិបត្តិការដូចខាងក្រោម៖

ល.រ	ប្រភេទប្រតិបត្តិការ	ជូនដំណឹងទៅកាន់
1	ការប្តូរកម្រិតសិទ្ធិប្រើប្រាស់គណនីក្រុម ពី Full Access ទៅ/មក View Only	▪ ម្ចាស់គណនីច្បង និងគ្រប់សមាជិកទាំងអស់ដែលមានសិទ្ធិ «ពេញលេញ/Full Access» និង «ពិនិត្យព័ត៌មាន/View Only»
2	ការបើកដំណើរការគណនីក្រុមឡើងវិញ/ Reactivate the Dormant Account	
3	ការដាក់ប្រាក់បញ្ញើ/Deposit	
4	ការដកប្រាក់បញ្ញើ/Withdrawal	
5	ការបន្ថែមសមាជិក/Add Member	
6	ការដកសមាជិក/Remove Member	
7	ការចាកចេញ/Leave Group	
8	ការបិទគណនី/Close Account	
9	គ្រប់ប្រភេទនៃប្រតិបត្តិការហិរញ្ញវត្ថុលើគណនីក្រុម	

27. **ការដោះស្រាយវិវាទសម្រាប់អតិថិជន** (Dispute Resolution)
    - លោក-លោកស្រី អាចស្នើសុំដោះស្រាយវិវាទ ឬ កែតម្រូវប្រតិបត្តិការ ដែលខ្លួនបានបញ្ជាពីគណនីក្រុមតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ជាលាយលក្ខណ៍អក្សរ ឬ តាមរយៈមន្ត្រីទំនាក់ទំនងអតិថិជន (Call Center)។
    - ខេប៊ីប្រាសាក់ នឹងព្យាយាមពិនិត្យ និងដោះស្រាយវិវាទឱ្យបានសមស្របទៅតាមនីតិវិធី។
28. **ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម** (Anti-Money Laundering and Combating Financing Terrorism)

    អនុលោមតាមបទប្បញ្ញត្តិទាំងឡាយ នៃ ព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លោក-លោកស្រីទទួលស្គាល់ និងយល់ព្រមថា ខេប៊ីប្រាសាក់ អាចនឹងពន្យារពេល បង្ខាំងគណនី ឬ បង្ខាំងសមតុល្យគណនីរបស់លោក-លោកស្រី ឬ មិនធ្វើប្រតិបត្តិការជូនលោក-លោកស្រីបាន ប្រសិនបើ ខេប៊ីប្រាសាក់មានការជឿជាក់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖
    - ខេប៊ីប្រាសាក់ មានការសង្ស័យចំពោះគោលបំណងនៃការបើកគណនី។
    - ប្រតិបត្តិការ ឬ គណនីរបស់លោក-លោកស្រី មានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយនឹងសកម្មភាពល្មើសច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ។
    - មានការបង្គាប់បញ្ជាពីអាជ្ញាធរមានសមត្ថកិច្ច ដូចជា តុលាការ ឬ ធនាគារជាតិ នៃ កម្ពុជា ជាដើម។

29. ការកែប្រែ អត្រាការប្រាក់ កម្រៃសេវា លក្ខខណ្ឌ និងការជូនដំណឹង

(Amendment of Interest Rate, Fees, Conditions and Notification)

29.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ អត្រាការប្រាក់ កម្រៃសេវា និងលក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តចំពោះការប្រើប្រាស់គណនីរបស់ លោក-លោកស្រី ដោយ ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងទៅលោក-លោកស្រី ឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

29.2. ក្នុងរយៈពេលនៃការជូនដំណឹង ករណីមិនមានការតវ៉ាពីលោក-លោកស្រី ត្រូវសន្មតថាអតិថិជនបានយល់ព្រម និងទទួលយកការកែប្រែខាងលើមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមាន ដែលត្រូវបានផ្សព្វផ្សាយតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

1) តាមរយៈសាខារបស់ខេប៊ីប្រាសាក់ និង/ឬ
2) តាមរយៈវេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ
3) ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់ លោក-លោកស្រី
4) តាមរយៈការផ្សព្វផ្សាយនៅលើទំព័រកាសែត ទស្សនាវដ្តី កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល ឬ មធ្យោបាយផ្សេងៗ ដែល ខេប៊ីប្រាសាក់ បានជ្រើសរើស។ល។

29.3. លោក-លោកស្រី ត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពី ខេប៊ីប្រាសាក់បានធ្វើការចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួន តាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

30. ច្បាប់ និងការដោះស្រាយវិវាទ (Law and Dispute Resolutions)

30.1. លក្ខខណ្ឌទូទៅនេះ ត្រូវបានគ្រប់គ្រង និងបកស្រាយដោយយោងតាមច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា។

30.2. ករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវដោះស្រាយដោយសន្តិវិធី។ ករណីវិវាទមិនអាចដោះស្រាយបានដោយសន្តិវិធី ឬ ក្រៅប្រព័ន្ធតុលាការ នោះវិវាទត្រូវដោះស្រាយទៅតាមប្រព័ន្ធតុលាការដោយយោងទៅតាមច្បាប់ នៃ ព្រះរាជាណាចក្រកម្ពុជា។

30.3. បញ្ហាផ្សេងៗ ដែលមិនមានចែងនៅក្នុងប្រការទាំងនេះ ត្រូវអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

30.4. រាល់លក្ខខណ្ឌផ្សេងៗ ដែលមិនមានចែងនៅក្នុងលក្ខខណ្ឌទូទៅនេះ ត្រូវអនុវត្តដោយយោងទៅតាម **«លក្ខខណ្ឌទូទៅនៃការប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ខេប៊ីប្រាសាក់»** ដែល លោក-លោកស្រី អាចស្វែងរកបាននៅតាមវេបសាយត៍ផ្លូវការរបស់ខេប៊ីប្រាសាក់ www.kbprasacbank.com.kh ឬ តាមសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិត លោក-លោកស្រី បំផុត។

31. **វិភាគភាព** (Severability)

ប្រសិនបើប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពតាមផ្លូវច្បាប់ ប្រការទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលប្រការនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃប្រការនោះតែប៉ុណ្ណោះ ចំណែកប្រការផ្សេងៗទៀតនៃកិច្ចព្រមព្រៀងនេះនៅតែបន្តមានសុពលភាពអនុវត្តដដែល។

32. **ភាសា** (Language)

លក្ខខណ្ឌនេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ និងអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសាខ្មែរចាត់ទុកជាផ្លូវការ៕